**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៣...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី២
## (Organizing Committee for Second AITEX 2007)
## នៅខេត្តសៀមរាប ពីថ្ងៃទី០១-០៣ ខែតុលា ឆ្នាំ២០០៧

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតជូនដំណឹងលេខ ៧៩១ សជណ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី២ (Organizing Committee for Second Angkor International Tourism Exchange AITEX 2007) ពីថ្ងៃទី០១-០៣ ខែតុលា ឆ្នាំ២០០៧ នៅខេត្តសៀមរាប រួមមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១- ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម ជុំ តៀន | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៥- ឯកឧត្តម កែវ សាវល | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៦- ឯកឧត្តម សូ ម៉ារ៉ា | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៧- ឯកឧត្តម ទី សាវី | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |

www.pheakdeylaw.com

៨- ឯកឧត្តម **គឹម គុណសម្បាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា សមាជិក

៩- ឯកឧត្តម **ទុំ ទាវីរិទ្ធ** អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក

១០- ឯកឧត្តម **នេត សាវឿន** អគ្គស្នងការរងនគរបាលជាតិ សមាជិក

១១- លោក **ទៅ ពិសិដ្ឋ** អភិបាលរងខេត្តសៀមរាប សមាជិក

១២- លោក **ឡាយ ចូន្នី** នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិក

**ប្រការ២ : គណៈកម្មការនេះមានភារកិច្ចដូចតទៅ:**

-សម្របសម្រួល និងគាំទ្រដល់ការរៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី ២ AITEX 2007 និងការសំដែងសិល្បៈ សកម្មភាព និងទស្សនីយភាពផ្សេងៗ នៅមជ្ឈមណ្ឌល Angkor COEX ខេត្តសៀមរាប ឱ្យបានជោគជ័យល្អប្រសើរ

-សហការជាមួយស្ថាប័នរដ្ឋនានា និងផ្នែកឯកជន ដើម្បីធ្វើការឃោសនា និងផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នេះ ឱ្យបានទូលំទូលាយទាំងក្នុង និងក្រៅប្រទេស

-សម្របសម្រួលជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ

-រៀបចំសម្រួលការធ្វើដំណើរ និងទទួលស្វាគមន៍គណៈប្រតិភូ និងភ្ញៀវទេសចរដែលមកចូលរួមក្នុងព្រឹត្តិការណ៍នេះឱ្យបានល្អ

-បូកសរុបចំណូល និងចំណាយ ព្រមទាំងរាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣** : -គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិកាក្រសួងទេសចរណ៍ក្នុងការបំពេញការងារ ។

-សមាជិកនៃគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

-គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការប្រតិបត្តិ និងអនុគណៈកម្មការទ្រទ្រង់ តាមការចាំបាច់របស់ខ្លួន ដើម្បីអនុវត្ត និងគ្រប់គ្រងការងាររៀបចំពិព័រណ៍ទេសចរណ៍អង្គរអន្តរជាតិលើកទី២ AITEX 2007 ។

**ប្រការ៤** : គណៈកម្មការនេះត្រូវចប់ភារកិច្ច និងរំសាយជាស្វ័យប្រវត្តិ នៅពេលចប់ព្រឹត្តិការណ៍នេះ ។

**ប្រការ៥** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន និងអភិបាលខេត្តសៀមរាប ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ៧ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com